**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤...[illegible]

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងឱកាសទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៧

- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី
- លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំព្រះករុណាខ្ញុំ សូមសំដែងនូវការអបអរសាទរជាមួយពិភពលោកទាំងមូល ចំពោះការប្រារព្ធទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងទិវាគ្រុនចាញ់ពិភពលោកដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧នេះ ក្រោមប្រធានបទ “ **បញ្ចប់ជំងឺគ្រុនចាញ់ អភិវឌ្ឍសហគមន៍** ” ក្នុងគោលបំណងជំរុញនិងបំផុសការយល់ដឹងនិងយកចិត្តទុកដាក់កាន់តែខ្ពស់បន្ថែមទៀត ក្នុងការលើកកម្ពស់សុខុមាលភាពសង្គម សំដៅរួមចំណែកដល់ការថែរក្សាសុខភាពរបស់ប្រជាពលរដ្ឋ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមសំដែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះគ្រប់សកម្មភាពទាំងអស់ដែលបាននិងកំពុងអនុវត្តក្នុងការជំរុញ និងបំផុសការយល់ដឹងជាសាធារណៈ និងការយល់ដឹងឱ្យកាន់តែទូលំទូលាយនៅទូទាំងប្រទេស ជាពិសេសនៅតាមទីជនបទ ដើម្បីផ្លាស់ប្តូរផ្នត់គំនិតនិងទម្លាប់របស់ប្រជាជនក្នុងការប្រតិបត្តិនៃការរស់នៅមានអនាម័យល្អ និងចៀសវាងការពារពីការចម្លងជំងឺគ្រុនចាញ់។ ពិតណាស់ថា ជំងឺគ្រុនចាញ់មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សុខភាពប៉ុណ្ណោះទេ តែវាធ្វើឱ្យខាតបង់ថវិកា តាមរយៈការចំណាយដោយផ្ទាល់លើការព្យាបាល ការខាតបង់ការងារ ការបាត់បង់ផលិតភាព និងអាយុជីវិត ថែមទាំងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរទៀតផង។ តាមទស្សនទាននេះ យើងទាំងអស់គ្នាចាំបាច់ណាស់ត្រូវបន្តយកចិត្តទុកដាក់លើការលុបបំបាត់ជំងឺគ្រុនចាញ់ ដោយមិនអាចមើលរំលងបានឡើយ។ ការប្រារព្ធទិវាគ្រុនចាញ់ក្រោមប្រធានបទ “ **បញ្ចប់ជំងឺគ្រុនចាញ់ អភិវឌ្ឍសហគមន៍** ” នេះសមស្របនឹងដំណើរវិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ខណៈដែលកម្ពុជាយើង មានអត្រាស្លាប់ដោយជំងឺគ្រុនចាញ់កាន់តែថយចុះជាលំដាប់ៗ។ កម្ពុជាបានបង្កើតផែនការយុទ្ធសាស្ត្រ

ជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ២០១១-២០២៥ ដែលជាផែនទីបង្ហាញផ្លូវ និងបង្កលក្ខណៈងាយស្រួលដល់ការប្រតិបត្តិជាក់ស្តែង លើការងារលុបបំបាត់ជំងឺគ្រុនចាញ់។

ចាប់តាំងពីឆ្នាំ២០១១ នៃការអនុវត្តផែនការយុទ្ធសាស្រ្តជាតិលុបបំបាត់ជំងឺគ្រុនចាញ់ ២០១១-២០២៥ របស់រាជរដ្ឋាភិបាល អត្រាជំងឺគ្រុនចាញ់នៅកម្ពុជាបានធ្លាក់ចុះជាលំដាប់។ ជាក់ស្តែង តាមរបាយការណ៍ប្រចាំឆ្នាំ សេវាសុខាភិបាលសាធារណៈរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ករណីស្លាប់ដោយសារជំងឺគ្រុនចាញ់ត្រូវបានកាត់បន្ថយប្រមាណ៩៨% គឺបានធ្លាក់ចុះពីចំនួន៩៣នាក់នៅឆ្នាំ២០១១ មកនៅត្រឹម០១នាក់ នៅឆ្នាំ២០១៦។ បើគិតជាអត្រាស្លាប់ក្នុងចំណោមមនុស្ស ១០០ ០០០នាក់ គឺថយចុះពី ០,៦៥នាក់ នៅឆ្នាំ២០១១ មកនៅត្រឹម ០,០១នាក់ នៅឆ្នាំ២០១៦។ ចំណែកឯ ករណីឈឺជំងឺគ្រុនចាញ់ត្រូវបានកាត់បន្ថយ ប្រមាណ៧៩% គឺបានធ្លាក់ចុះពីចំនួន ៦២ ៦៩០ករណី នៅឆ្នាំ២០១១ មកនៅត្រឹម ២៣ ៦២៧ករណី នៅឆ្នាំ២០១៦ ហើយចំនួនករណីជំងឺគ្រុនចាញ់ ក្នុងចំណោមប្រជាជន ១ ០០០នាក់ បានថយចុះពី ៧,៨៤នាក់ នៅឆ្នាំ២០១១ មកនៅត្រឹម ១,៥នាក់ នៅឆ្នាំ២០១៦។ ករណីជំងឺគ្រុនចាញ់ មានចំនួនសរុប ២៣ ៦២៧ករណី នៅឆ្នាំ២០១៦ ថយចុះ ៥៤% បើធៀបនឹងឆ្នាំ២០១៥ ដែលមាន ៥១ ២៦២ករណី និងស្លាប់១០នាក់។ ក្នុងន័យនេះ យើងអាចនិយាយបានថា ការប្រយុទ្ធនឹងជំងឺគ្រុនចាញ់របស់យើងកាន់តែមានប្រសិទ្ធភាពខ្ពស់ ហើយបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សប្រទេសកម្ពុជាយើងមុនកាលកំណត់ និងស្ថិតនៅលើវិថីនៃការលុបបំបាត់ជំងឺគ្រុនចាញ់។

ទោះបីយ៉ាងណាក៏ដោយ ក៏យើងមិនត្រូវភ្លេចខ្លួន ហើយស្កប់ស្កល់នឹងលទ្ធផលដែលយើងទទួលបាននោះទេ ព្រោះថាជំងឺគ្រុនចាញ់នៅតែជាបន្ទុកដ៏ធ្ងន់មួយរបស់កម្ពុជា ហើយបើយើងមិនទាន់លុបបំបាត់មេរោគគ្រុនចាញ់ឱ្យអស់ពីក្នុងខ្លួនមនុស្សគ្រប់រូបទេនោះ មូសដែកគោលញីដែលនៅបន្តមានវត្តមានក្នុងព្រៃ និងតំបន់ជុំវិញ នៅតែមានឱកាសនាំបីតឈាមចម្លងមេរោគគ្រុនចាញ់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ និងពីសហគមន៍មួយទៅសហគមន៍មួយទៀត។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលតែងបានផ្តល់លទ្ធភាព និងលើកទឹកចិត្តឱ្យមានចលនាប្រមែប្រមូលប្រភពធនធានដើម្បីជំរុញការងារប្រយុទ្ធនឹងជំងឺគ្រុនចាញ់ឱ្យកាន់តែសកម្មថែមទៀត សំដៅលុបបំបាត់ជំងឺនេះឱ្យសម្រេចតាមផែនការកំណត់។ ដូច្នេះយើងត្រូវយកចិត្តទុកដាក់ខ្ពស់ទាំងអស់គ្នាលើចំណុចទាំងនេះ ដើម្បីលើកកម្ពស់សុខភាពគុណភាពនៃការរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋយើង។

ក្នុងនាមរាជរដ្ឋាភិបាល និងខ្លួនខ្ញុំព្រះករុណាផ្ទាល់ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណដល់ភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុង និងក្រៅប្រទេស រួមទាំងមន្ត្រី បុគ្គលិកសុខាភិបាល ប្រជាជនគ្រប់រូប ដែលបានធ្វើឱ្យសម្រេចជោគជ័យនូវសមិទ្ធផលលើការងារប្រយុទ្ធនឹងជំងឺគ្រុនចាញ់នាពេលកន្លងមក និងសូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងដល់សកម្មភាពប្រយុទ្ធនឹងជំងឺគ្រុនចាញ់ក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាទូទាំងសកលលោក។ ទន្ទឹមនឹងនេះ ខ្ញុំសូមអំពាវនាវឱ្យក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ វិស័យឯកជន អង្គការនានា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន សហគមន៍ជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ជាពិសេសប្រជាជនគ្រប់រូប សូមបន្តចូលរួម និងគាំទ្រដល់បេសកកម្មរបស់ក្រសួងសុខាភិបាលក្នុងការលុបបំបាត់ជំងឺគ្រុនចាញ់ឱ្យទទួលបានជោគជ័យ និងសម្រេចតាមគោលដៅយុទ្ធសាស្រ្តជាតិលុបបំបាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០១១-២០២៥។

**មុននឹងបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមឱ្យខ្លឹមសារ និងអត្ថន័យនៃទិវាគ្រុនចាញ់ពិភពលោក ២៥ មេសា ២០១៧ ក្រោមពាក្យស្លោកថា "បញ្ចប់ជំងឺគ្រុនចាញ់ អភិវឌ្ឍសហគមន៍" ក្លាយទៅជាការអនុវត្តន៍ជាក់ស្តែង កាន់តែស៊ី**

ជម្រៅ កាន់តែទូលំទូលាយ និងកាន់តែគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យព្រះរាជាណាចក្រកម្ពុជាយើង អាចធ្វើដំណើរឆ្ពោះទៅកាន់អនាគតមួយ ដែលគ្មានជំងឺគ្រុនចាញ់។ ខ្ញុំព្រះករុណាខ្ញុំ សង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន ភាគីពាក់ព័ន្ធវិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ សប្បុរសជន ព្រះសង្ឃ និងប្រជាពលរដ្ឋទាំងអស់ នឹងបន្តចូលរួមចំណែក និងគាំទ្រដល់ការលើកកម្ពស់ការលុបបំបាត់ជំងឺគ្រុនចាញ់ ក្នុងបុព្វហេតុរួមចំណែកលើកកម្ពស់ថែមទៀតនៅឧត្តមភាព និងកិត្យានុភាពកម្ពុជា។

ជាទីបញ្ចប់ ជាមួយនឹងឱកាសនៃការប្រារព្ធទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងទិវាគ្រុនចាញ់ពិភពលោកនេះ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**